ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## នីតិវិធីនៃការអនុវត្តន៍ វិន័យចំពោះមន្ត្រីរាជការស៊ីវិល

◇◇◇◇◇◇◇◇◇

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល.
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤.
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៦ នស.៩៤. ចុះថ្ងៃទី៣០ខែតុលា ឆ្នាំ១៩៩៤.
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២៤ ចុះថ្ងៃទី២៤ មករា ១៩៩៦ ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ.
- តាមសំណើរបស់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- ដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីផង

## សំរេច

### ជំពូកទី១

### កំហុសខាងវិន័យ

មាត្រា១ : កំហុសខាងវិន័យគឺការកើតឡើងពីការប្រព្រឹត្តិ ដោយចេតនា ឬអចេតនា ការខកខានមិនបានប្រព្រឹត្តិ ការភ្លេចភ្លាំង ការធ្វេសប្រហែស ការខ្ជីខ្ជា និងរាល់ការបំពានទៅលើជំពូកទី៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៣ ៣៤ ៣៥ ៣៧ ៣៨ ៣៩ ដែលកំណត់តាមឆន្ទានុសិទ្ធិ នៃអាជ្ញាធរដាក់វិន័យថា ជាការខ្វះខាតក្នុងកាតព្វកិច្ចបំពេញការងារ ។

មាត្រា២ : រាល់កំហុសខាងវិន័យ ដែលប្រព្រឹត្តដោយអ្នករាជការណាម្នាក់តំរូវអោយអ្នករាជការនោះទទួលទណ្ឌកម្មខាងវិន័យ ដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។ កំហុសខាងវិន័យ កំហុសខាងរដ្ឋប្បវេណី និងកំហុសខាងព្រហ្មទណ្ឌមានភាពស្វយ័តរវាងគ្នា ។ ទណ្ឌកម្មរដ្ឋប្បវេណី ឬទណ្ឌកម្មព្រហ្មទណ្ឌ ក៏មានភាពស្វយ័តរវាងគ្នាដែរ ។

### ជំពូកទី២

### និតិវិធីអនុវត្តវិន័យពាក់ព័ន្ធនឹងទណ្ឌកម្មថ្នាក់ទី ១

មាត្រា៣ : មន្ត្រីរាជការជាប់ចោទប្រកាន់មានសិទ្ធិសុំមើលសំណុំរឿងខ្លួន តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ការសុំមើលសំណុំរឿងត្រូវធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីបានទទួលដំណឹងជាផ្លូវការ ពីប្រធានអង្គភាព ឬស្ថាប័នសាមី ។ អ្នកទទួលខុសត្រូវសំណុំរឿងត្រូវរក្សាការសំងាត់នូវឈ្មោះសាក្សី ។ សាមីខ្លួនអាចធ្វើលិខិតតវ៉ាទៅប្រធានស្ថាប័នក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ ក្រោយពីបានមើលសំណុំរឿង ។

មាត្រា៤ : ក្រោយពីបានទទួលការពន្យល់ដោះសា ឬក្នុងករណីដែលគ្មានការដោះសាពីអ្នករាជការក្នុងរយៈពេលកំណត់ដូចខាងលើ ប្រធានស្ថាប័នអាចសំរេចយកចំណុចណាមួយដូចខាងក្រោម :

- ទុកសំណុំរឿងដោយមិនបាច់មានវិធានការបន្ត
- ធ្វើការស្តីបន្ទោស
- មានវិធានការដាក់ទណ្ឌកម្មខាងវិន័យ ថ្នាក់ទីមួយផ្សេងទៀតតាមនីតិវិធី ។

**មាត្រា៥ :** រូបភាពវិន័យស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួនដោយប្រធានអង្គភាពឬប្រធានស្ថាប័ន។ លិខិតស្តីបន្ទោសនេះ អស់ប្រសិទ្ធិភាពក្រោយរយៈពេល ១ឆ្នាំ លើកលែងតែក្នុងរយៈពេលនោះ សាមីខ្លួន បានប្រព្រឹត្តខុសឆ្គងអ្វីមួយបន្ថែមទៀត ។រូបភាពវិន័យស្តីបន្ទោសដែលមានចំណារក្នុង សំណុំលិខិតផ្ទាល់ខ្លួនការផ្លាស់ដោយបង្ខំ និងការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬ ថ្នាក់ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស។

ការស្តីបន្ទោសដែលមានចំណារក្នុងសុំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំអាច មានប្រសិទ្ធិភាពរយៈពេល ២ឆ្នាំ ក្នុងករណីសាមីខ្លួនមិនបានប្រព្រឹត្តិខុសថ្មីទៀត ។

ចំពោះការផ្លាស់ដោយបង្ខំសាមីខ្លួនពុំមានសិទ្ធិវិលត្រឡប់មកកាន់តំណែងដើមវិញ ជាស្វ័យប្រវត្តិ ។

ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិឬថ្នាក់ត្រូវអនុវត្តក្នុងឆ្នាំរហូតដល់ពេល ធ្វើតារាងឡើងឋានន្តរសក្តិឬថ្នាក់នៃឆ្នាំបន្ទាប់។

ទណ្ឌកម្មនេះនឹងអស់ប្រសិទ្ធិភាពលុះណាតែក្នុងរយៈពេលខាងលើ សាមីខ្លួនពុំបាន ប្រព្រឹត្តិខុសឆ្គងអ្វីមួយបន្ថែមទៀត ហើយករណីនេះត្រូវបញ្ជាក់ច្បាស់ក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសដាក់ទណ្ឌកម្ម ។

## ជំពូកទី៣

## នីតិវិធីអនុវត្តវិន័យពាក់ព័ន្ធនឹងទណ្ឌកម្មថ្នាក់ទី ២

**មាត្រា៦ :** រូបភាពវិន័យថ្នាក់ទី២ មាន :

ក. ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ឬ ថ្នាក់បើសិនជាមាន ចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការឡើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងវេលាមួយមានកំណត់តែមិន ត្រូវអោយលើសពី២ឆ្នាំក្នុងការតម្លើងឋានន្តរស័ក្តិឬថ្នាក់តាមវេនជ្រើសរើសឬតាមវេនអតីតភាព។

ខ. ដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនឱ្យលើសពី១ឆ្នាំ ។

គ. បន្ថយឋានន្តរស័ក្តិ ឬថ្នាក់ ១ថ្នាក់ ឬច្រើនថ្នាក់ ។

ឃ. ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ ។

ង. បណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ ។

ការចោទប្រកាន់អំពីកំហុសខាងវិន័យថ្នាក់ទី២ ត្រូវមានការអង្កេតជាមុនសិន ។

ការអង្កេតត្រូវប្រគល់ឱ្យតំណាងប្រធានស្ថាប័នសាមីមួយរូប ឬ ច្រើនរូប ដែលមានឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាង ឬមានឋានន្តរស័ក្តិស្មើគ្នា តែមានអតីតភាពការងារច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទប្រកាន់ ។ ក្នុងការអង្កេតសាមីខ្លួន ត្រូវបានអញ្ជើញជាផ្លូវការមកមើលសំណុំរឿងខ្លួន និងតវ៉ាតាមលក្ខខ័ណ្ឌ និងពេលវេលាដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។ ការអង្កេតនេះមានរយៈពេល២ខែ យ៉ាងយូរ ។

សំណុំរឿងអង្កេតរួចហើយត្រូវបញ្ជូនទៅប្រធានស្ថាប័ន ដើម្បីពិនិត្យនិងសំរេចថា គួរបញ្ជូនអ្នករាជការជាប់ចោទប្រកាន់នោះ ឱ្យទៅក្រុមប្រឹក្សាវិន័យ ឬក៏សំរេចថា បញ្ឈប់ការចោទប្រកាន់វិញ ឬដាក់វិន័យត្រឹមថ្នាក់ទី១ ។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថា គួរបន្តការចោទប្រកាន់សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យ ។

របាយការណ៍ឬការវាយតម្លៃរបស់អធិការដ្ឋាន ឬអគ្គាធិការដ្ឋាន មានលក្ខណៈចាំបាច់សំរាប់ប្រធានស្ថាប័ន ក្នុងករណីដែលការចោទប្រកាន់មិនប៉ះពាល់ដល់អធិការឬអគ្គាធិការ ។

មាត្រា៧ : ការតែងតាំងក្រុមប្រឹក្សាវិន័យត្រូវសំរេចដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។ ក្រុមប្រឹក្សាវិន័យត្រូវបានបង្កើតឡើងទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលមានបញ្ហាខាងវិន័យកើតឡើង ។

មាត្រា៨ : ក្រុមប្រឹក្សាវិន័យត្រូវមានសមាជិក ៥រូប :

-អ្នករាជការ៣នាក់ ចាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការ ជាប់ចោទប្រកាន់នោះនៅក្រោមឱវាទក្នុងនោះម្នាក់បំពេញមុខងារជាប្រធាន ម្នាក់ទៀតបំពេញមុខងារ ជាសមាជិករាយការណ៍ និងអ្នកទី៣ ជាសមាជិក ។

-អ្នករាជការ ២នាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា នឹងអ្នករាជការជាប់ចោទប្រកាន់ ក៏ប៉ុន្តែមាន ឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។

ក្នុងករណីអគ្គនាយក ឬអគ្គាធិការ ត្រូវបញ្ជូនទៅក្នុងក្រុមប្រឹក្សាវិន័យ ក្រុមប្រឹក្សាវិន័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្នុងចំណោមមន្ត្រីរាជការ ដែលមានក្របខ័ណ្ឌជាមួយគ្នា មានឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាង ក្នុងថ្នាក់ស្មើគ្នា ដែលធ្វើការនៅអង្គភាពផ្សេង នៃស្ថាប័នជាមួយគ្នា ។ ក្នុងករណីពុំមានមន្ត្រីរាជការ ដូចពោលខាងលើរាជរដ្ឋាភិបាលស្នើសុំសំរេចតែងតាំងក្រុមប្រឹក្សាវិន័យ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់មកពីស្ថាប័នផ្សេងៗក៏បាន ។

មិនអាចចាត់តាំងអោយចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណា ដែល

ជាអ្នកធ្វើពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទប្រកាន់ ឬជាក្រុមញាតិ រហូតដល់ជូរទីតា របស់អ្នករាជការជាប់ចោទប្រកាន់នោះ ។

មាត្រា៩ : ក្រោយពេលក្រុមប្រឹក្សាវិន័យត្រូវបានតែងតាំងរួចហើយ ប្រធានស្ថាប័ន ដែលគ្រប់គ្រងអ្នករាជការនោះ ត្រូវបញ្ជូនសំណុំរឿងទាំងអស់ ពាក់ពន្ធ័នឹងអ្នករាជការជាប់ចោទប្រកាន់ ទៅអោយប្រធានក្រុមប្រឹក្សាវិន័យ ដែលត្រូវបញ្ជូនទៅឱ្យសមាជិករាយការណ៍ ។

មាត្រា១០: សមាជិករាយការណ៍ត្រូវអោយអ្នករាជការជាប់ចោទប្រកាន់មើលសំណុំរឿងផ្ទាល់ខ្លួន និងឱ្យផ្តល់នូវបញ្ជីកសិណសាក្សី ព្រមទាំងឈ្មោះតំណាងការពារខ្លួន ។ បន្ទាប់មកសមាជិករាយការណ៍ត្រូវធ្វើអង្កេតស៊ើបសួររឿងនោះដោយ :

-ទាររកសំអាងផ្សេងៗ បើសិនជាការចាំបាច់ ។

-ស្រង់យកចម្លើយរបស់កសិណសាក្សីបើសិនជាមាន ។

-ស្តាប់ការពន្យល់ផ្ទាល់មាត់ និងមតិតំណាងការពារដែលជាអ្នករាជការ ។

-ទទួលយកពាក្យតវ៉ារបស់អ្នករាជការជាប់ចោទប្រកាន់ ។

សមាជិករាយការណ៍ ត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរពីលទ្ធផលអង្កេត ដោយមិនបញ្ចេញយោបល់ផ្ទាល់ខ្លួនក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ ហើយបញ្ជូនរបាយការណ៍ជាបន្ទាន់ទៅប្រធានក្រុមប្រឹក្សាវិន័យ ។

មាត្រា១១: ក្រោយពេលដែលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំយ៉ាងយូរក្នុងរយៈពេល១៥ថ្ងៃ។ ក្នុងករណីសំណុំលិខិតមិនទាន់គ្រប់គ្រាន់ ប្រធានអាចបង្គាប់ឱ្យសមាជិករាយការណ៍រកពត៌មានបន្ថែមទៀតនិងពន្យាពេលប្រជុំទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារៈប្រយោជន៍ដើម្បីរកការពិត និងកុំឱ្យប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យ របស់តុលាការក្នុងករណីដែលតុលាការបានសំរេចពីមុនមកហើយ ។

ការស្រាវជ្រាវខាងលើនេះ មិនត្រូវអោយលើសពី ២ខែឡើយ ។

ក្នុងករណីចាំបាច់ដែលមានភាពពិបាកក្នុងការស្រាវជ្រាវពត៌មានប្រធានក្រុមប្រឹក្សាវិន័យអាចពន្យារពេលប្រជុំបានត្រឹមតែ ២ខែទៀត ។

មាត្រា១២: ក្រុមប្រឹក្សាវិន័យបើកការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ដោយត្រូវតែមានវត្តមានសមាជិកគ្រប់ចំនួន ។ក្នុងករណីដែលសមាជិកណាមួយអវត្តមាន ដោយមានធុរៈ ប្រធានស្ថាប័ន ត្រូវ

មានវិធានការបំពេញបន្ថែមសមាជិកថ្មី ជំនួសបង្គ្រប់ ។ អ្នករាជការជាប់ចោទប្រកាន់ ត្រូវតែចូលបង្ហាញខ្លួនតាមការអញ្ជើញនោះ ។ អ្នករាជការជាប់ចោទប្រកាន់ ដែលចូលបង្ហាញខ្លួនតាមការអញ្ជើញ អាចនាំតំណាងការពារខ្លួន ដែលជាអ្នករាជការ និងសាក្សីមកជាមួយ ។

អ្នករាជការជាប់ចោទប្រកាន់នោះ អាចដោះសាបំភ្លឺការពារខ្លួនឯង ឬតាមរយៈតំណាង ការពារខ្លួនដោយផ្ទាល់មាត់ ឬដោយលាយលក្ខ័អក្សរ ។

មាត្រា១៣: ក្រោយពីពិភាក្សាសាកសួរយកពត៌មានចប់សព្វគ្រប់ហើយ ក្រុមប្រឹក្សាវិន័យថយទៅពិគ្រោះពិចារណា សន្និដ្ឋានដោយសម្ងាត់ ។ បន្ទាប់មកក្រុមប្រឹក្សាវិន័យធ្វើការបោះឆ្នោត ដោយសម្ងាត់ជាបន្តបន្ទាប់ ចាប់តាំងពីទណ្ឌកម្មខាងវិន័យកំរិតខ្ពស់បំផុតចុះមក ។ ការបើកសន្លឹកឆ្នោតត្រូវបើកទាំងអស់តែម្តងនៅពេលបោះឆ្នោតតាមកំរិតទណ្ឌកម្មនីមួយៗ រួចហើយបើមានសម្លេងស្មើគ្នាត្រូវបោះឆ្នោតលើកំរិតទណ្ឌកម្មខាងវិន័យនោះម្តងទៀត ។

មាត្រា១៤: កំណត់ហេតុលទ្ធផលនៃការពិភាក្សា និងការបោះឆ្នោតសម្ងាត់នេះប្រធាន ក្រុមប្រឹក្សាវិន័យត្រូវធ្វើភ្លាម រួចបញ្ជូនទៅប្រធានស្ថាប័នសាមី ព្រមទាំងធ្វើសេចក្តីជូនដំណឹងមួយទៀត ស្តីអំពីកំរិតទណ្ឌកម្ម ខាងវិន័យ បញ្ជូនទៅសាមីខ្លួន អោយទទួលយកដោយមានចុះហត្ថលេខាបញ្ជាក់មកវិញផង ។ ក្នុងករណី ដែលមន្ត្រីរាជការជាប់ចោទប្រកាន់ មិនព្រមទទួលសេចក្តីជូនដំណឹងនេះទេ ក្រុមប្រឹក្សាវិន័យ ក៏នៅតែមានសិទ្ធិ បញ្ជូនសំណុំរឿងទៅប្រធានស្ថាប័នពិនិត្យ និងសំរេចដោយរាយការណ៍ជាលាយល័ក្ខអក្សរថា សាមីខ្លួនមិនព្រមចុះហត្ថលេខាលើសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាវិន័យទេ ។

មាត្រា១៥: ថ្នាក់មានសមត្ថកិច្ចក្នុងការសំរេចដាក់ទណ្ឌកម្មខាងវិន័យមិនចាំបាច់ថាត្រូវតែសំរេចតាមយោបល់របស់ក្រុមប្រឹក្សាវិន័យឡើយ ។ ក្នុងករណីដែលក្រុមប្រឹក្សាវិន័យយល់ឃើញថា មានកំហុសថ្នាក់មានសមត្ថកិច្ចអាចមិនយកតាមយោបល់របស់ក្រុមប្រឹក្សាវិន័យ ដោយបញ្ជាក់ពីមូលហេតុជាលាយលក្ខ័អក្សរ និងសំរេចដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ណាមួយស្រាលជាងសំណើរបស់ក្រុមប្រឹក្សា វិន័យ ។

មាត្រា១៦: ទណ្ឌកម្មជាស្ថាពរ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។

## ជំពូកទី៤

## និតិវិធីអនុវត្តវិន័យចំពោះអ្នករាជការជាប់ចោទប្រកាន់ពីបទវិន័យដែលបាត់ខ្លួនរកពុំឃើញ

**មាត្រា១៧:** ក្នុងពេលអនុវត្តនិតិវិធីដាក់វិន័យ បើអ្នករាជការជាប់ចោទប្រកាន់បាត់ខ្លួនរកពុំឃើញ ក្នុងរយៈពេល ១៥ថ្ងៃ ជាបន្តបន្ទាប់ក្រោយពីការអញ្ជើញពីរលើក ត្រូវដាក់ឱ្យនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ។ ផុតរយៈពេល ៣ខែ បើសាមីជនជាប់ចោទប្រកាន់នៅតែរកពុំឃើញ ក្រោយពីការជូនដំណឹង ២ដង ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ ។

## ជំពូកទី៥

### អវសានប្បញ្ញត្តិ

**មាត្រា១៨:** បទបញ្ញត្តិ ទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១៩:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៨ ខែ មករា ឆ្នាំ១៩៩៧ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានក្រាបបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

**រដ្ឋលេខាធិការ**

នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រាក់ សុខ

កន្លែងទទួល:

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

-ដូចមាត្រា១៩

# គំនូសបំព្រួញ

## ដំណាក់នៃ នីតិវិធីដាក់វិន័យមន្ត្រីរាជការ

កំហុសនៃមន្ត្រីរាជការ

ការសុំឱ្យពន្យល់ពីកំហុសដោយប្រធានស្ថាប័នតាមលិខិតជូនដំណឹងផ្លូវការ

ពិនិត្យសំណុំរឿងដោយមន្ត្រីរាជការក្រោយពីបានទទួលដំណឹងជាផ្លូវការរយៈពេល១៥ថ្ងៃ

ការបញ្ជូនសារណាការពារខ្លួនទៅប្រធានស្ថាប័នរយៈពេល ១៥ថ្ងៃ

សេចក្តីសំរេចរបស់ប្រធានស្ថាប័ន : ទុកសំណុំរឿងមិនចាត់ការ / ស្តីបន្ទោស/
មានវិធានការ / ដាក់វិន័យតម្រូវតាមនីតិវិធី

ប្រធានស្ថាប័នសំរេចឱ្យអនុវត្តនីតិវិធីដាក់វិន័យថ្នាក់ទី២ ក្នុងករណីដែលកំហុស
មានលក្ខណៈធ្ងន់ធ្ងរ

ការស៊ើបអង្កេត របស់តំណាងស្ថាប័នមួយ ឬច្រើនរូបចាត់តាំងដោយប្រធានស្ថាប័នក្នុង
រយៈពេលពេល ១៥ថ្ងៃ

សេចក្តីសំរេចរបស់ប្រធានស្ថាប័នទុកសំណុំរឿងមិនចាត់ការដាក់ទណ្ឌកម្មថ្នាក់ទី១ ឬបញ្ជូន
សំណុំរឿងទៅក្រុមប្រឹក្សាវិន័យ

ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សំរេចឱ្យអនុវត្តនីតិវិធីដាក់វិន័យថ្នាក់ទី២

ការស៊ើបអង្កេតដំបូងដោយសមាជិករាយការណ៍រយៈពេល ១៥ថ្ងៃ

ក្រុមប្រឹក្សាវិន័យទទួលរបាយការណ៍ និងកោះប្រជុំក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរឬ
បញ្ជូនសំណុំលិខិតទៅសមាជិករាយការណ៍ក្នុងករណីសំណុំរឿងពុំទាន់ច្បាស់លាស់

សមាជិករាយការណ៍ នៃក្រុមប្រឹក្សាវិន័យស៊ើបអង្កេតរយៈពេល ២ខែ

ការសន្និដ្ឋានរបស់ក្រុមប្រឹក្សាវិន័យក្នុងករណីដែលសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់
ឬបញ្ជូនសំណុំរឿងទៅសមាជិករាយការណ៍ក្នុងករណីសំណុំរឿងមិនទាន់គ្រប់គ្រាន់

ការស៊ើបអង្កេតបន្ថែមដោយសមាជិករាយការណ៍រយៈពេល ២ខែ

កោះប្រជុំក្រុមប្រឹក្សាវិន័យ ដើម្បីសន្និដ្ឋានជូនប្រធានស្ថាប័ន

សេចក្តីសំរេចដាក់វិន័យរបស់ប្រធានស្ថាប័ន